សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
Free
KhmerPost USA
www.khmerpostusa.com

FREE COPIES
Vol. 13. Issue #279
Sept 09, 2019
www.khmerpostusa.com
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

**ព័ត៌មានសំខាន់ៗខាងក្នុង...**

ប្រជាមតិស្តីពីពិធីបោះឆ្នោត... *Page 02*



ព្យុះសង្ឃរាDORIAN បានសម្លាប់មនុស្ស៤៣នាក់
*ទំព័រ ០៣*



លោក សម រង្ស៊ី បំពងសម្លេងសារជាថ្មី...
*ទំព័រ ០៨*



# បោះឆ្នោតក្រុមប្រឹក្សាក្រុងនៅឡូវែលជុំទី១ ថ្ងៃអង្គារទី២៤ កញ្ញា ឆ្នាំ២០១៩

រូបថតសមាជិកក្រុមប្រឹក្សាក្រុងឡូវែលបច្ចុប្បន្ន -អ្នកទាំងអស់នេះ និងត្រូវចប់អាណត្តិចុងឆ្នាំ២០១៩ - សមាជិកទាំងអស់បានឈរឈ្មោះជាបេក្ខជនសម្រាប់អាណត្តិថ្មី( លើកលែង២រូប) ជាបន្តទៅទៀត -សូមអញ្ជើញតាមដានបេក្ខជនសមាជិកក្រុមក្រុងទាំងអស់ ចំនួន២០រូប នៅទំព័រ ០៥ -នៅទំព័រទី៤ មានរូបថតរបស់បេក្ខជនគណកម្មការសាលារៀនចំនួន១១រូប ។



ជួរមុខ: ទី១-លោកស្រី រីដា មើស្សេ, ទី២-លោក បៀល សាម៉ារ៉ាស់ អភិបាលក្រុង, ទី៣-លោក វ៉ាសនា នួន ជាអភិបាលក្រុងរង, ទី៤-លោកស្រី ហ្គារ៉ែន ស៊ីរីលោ,

ជួរក្រោយ : ទី៥-លោក ដេវ ខុនវ៉េ, ទី៦- លោក រ៉តនី អ៊ីលីយ៉ុត, ទី៧-លោក មីលីណាហ្សេ្យ ឥតឈរឈ្មោះទៀតទេ, ទី៨-លោក អែត ខេណីឌី ទើបនឹងជាប់ជាព្រឹទ្ធសមាជិកឥឈរឈ្មោះទៀតទេ , ទី៩-លោក ចន លីហ៊ី

សូមអានជាបន្តនៅទំព័រទី០៤ និងទី០៥



មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL
សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987
Excellent Service Since 1987
គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា
សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ
Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense
Thank you for your continued confidence
In our office to handle your legal and tax matters.
We look forward to serving you well into the future.
16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# ប្រជាមតិស្ដីពីវិធីបោះឆ្នោតឡូវែលសម្រាប់ឆ្នាំ ២០២១តទៅ

ដោយ ពិន សំខុន

លោក វ៉ាស្នា នួន បានផ្ដល់ព័ត៌មានស្ដីអំពីបណ្ដឹងពីការបោះឆ្នោតរបស់ជនភាគតិច ចំពោះសាលាក្រុងឡូវែលថា "គត់មានបណ្ដឹងអ្វីតទៅទៀតទេ!" លោកបាន បន្តថា: សមាជិកក្រុមប្រឹក្សាក្រុងឡូវែលបានសម្រេច កាលពីថ្ងៃអង្គារកន្លងទៅយករូបមន្ត២ សម្រាប់ស្នើឱ្យមានការកែប្រែវិធីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាសាលាក្រុងនឹងគណកម្មការសាលារៀន សម្រាប់ការបោះឆ្នោតឆ្នាំ២០២១ សម្រាប់តាំងសំនួរប្រជាមតិនៅពេលបោះឆ្នោតខាងមុខជូនប្រជាពលរដ្ឋឡូវែលឱ្យជ្រើសយកណាមួយដែលខ្លួនយល់ថា ប្រសើរជាងគេសម្រាប់ជ្រើសយកឱ្យបានតំណាងជនភាគតិចអាចជាប់ជាតំណាងនៅសាលាក្រុងតំបន់របស់ខ្លួន ចាប់តាំងពីឆ្នាំ២០២១តទៅ។


វិសនា នួន

សំនួរដែលនៅសល់តែ២ បន្ទាប់ពីចម្រាញ់ចេញពីរូបមន្ត៧យ៉ាង សម្រាប់ប្ដូររបៀបបោះឆ្នោតនៅឡូវែល ដែលអាចឱ្យសំណាងច្រើនដល់ប្រជាជនភាគតិច មានជនជាតិអាមេរិកាំងដើមកំណើតខ្មែរក្ដីឬក៏ជនជាតិអាមេរិកាំងដើមកំណើតស្បានីសក្ដី តើគេត្រូវយកណាមួយនោះគឺ:

ជម្រើសទី១-បោះឆ្នោតឱ្យមានសមាជិកក្រុមប្រឹក្សាក្រុងកើនចំនួនពី៩រូប ទៅចំនួន១១រូបគឺ: ៨រូបជាប់ឆ្នោតដោយតំបន់ឡូវែល ដែលនឹងត្រូវបែងចែកជា៨ សម្រាប់ឱ្យប្រជាពលរដ្ឋបោះឆ្នោតក្នុងតំបន់ (by districts) ជ្រើសរើសដំណាងឱ្យបានម្នាក់ ចេញពីតំបន់ (District)រៀងៗខ្លួន, នឹងមាន៣រូបទៀត ដែលនឹងជាប់ឆ្នោតដោយប្រជាពលរដ្ឋឡូវែលទាំងមូល (At large) ដែលយ៉ាងហោចណាស់ឱ្យមាន២នាក់ជាដំណាងឱ្យជនជាតិភាគតិច។

សម្រាប់គណកម្មការសាលារៀនវិញ មានចំនួន៦រូបគឺ: ៤រូបជាប់ឆ្នោតដោយការចែកឡូវែលជា៤តំបន់ (District) ហើយពលរដ្ឋក្នុងតំបន់និមួយៗនឹងជ្រើសយកតំណាងរបស់ខ្លួនម្នាក់, ២រូបទៀត នឹងជាប់ឆ្នោតដោយពលរដ្ឋឡូវែលទាំងមូល (At large)តែត្រូវឱ្យមានម្នាក់មកពីតំណាងរបស់ជនជាតិភាគតិច។

ជម្រើសទី២-ក្នុងរូបមន្តដដែល ដែលមានចំនួនអ្នកជាប់ឆ្នោតតំបន់នឹងឡូវែលទាំងមូលដដែលអ្នកបោះឆ្នោតអាចជ្រើសរើសបេក្ខជន តាមលំដាប់ថ្នាក់ដែលខ្លួនពេញចិត្ត (by Ranked choise)បាន... បានន័យថា អ្នកដែលបានលំដាប់ថ្នាក់ពេញចិត្តច្រើន ក៏អាចឈ្នះលើអ្នកដែលទទួលបានសន្លឹកឆ្នោតច្រើនបានដែរ។

លោក វ៉ាស្នា នួន យល់ថា: លោកចូលចិត្ត ជម្រើស ទី១ ជាងគេ ពីព្រោះ វានឹងអនុញ្ញាត្តិឱ្យជនជាតិភាគតិចងាយស្រួលនឹង ជាប់ឆ្នោតជាងមុន ហើយ ចំណាយលុយតិចសម្រាប់បេក្ខជនធ្វើការឃោសនាផង។

លោក សុខារី ចៅ បេក្ខជនក្រុមប្រឹក្សាក្រុងថ្មី និយាយថា: គឺជាការផ្លាស់ប្ដូរដ៏សំខាន់មួយសម្រាប់សហគមន៍យើង, ខ្ញុំចូលចិត្តជម្រើសទី១ ពីព្រោះវាស្រួលយល់ ហើយស្រដៀងគ្នាការបោះឆ្នោតលើកមុនៗ, ហើយយើងក៏មានលទ្ធភាពនឹងជ្រើសរើសបេក្ខជនក្នុងតំបន់ម្នាក់ហើយនឹងសំរាប់ក្រុងទាំងមូលម្នាក់ទៀត, ប៉ុន្តែខ្ញុំមិនចូលចិត្តឃើញបេក្ខជនតំបន់ផ្សេងមកឈរឈ្មោះក្រៅតំបន់ដែលខ្លួនរស់នៅបាននោះទេ។ ចំណែកឯជម្រើសទី២ ផ្ដល់ការលំបាកនឹងយល់ពីវិធីបោះឆ្នោតណាស់ ពីព្រោះគេត្រូវស្គាល់បេក្ខជនឱ្យបានច្បាស់ឱ្យបានច្រើន ដើម្បីធ្វើការប្រៀបធៀបឱ្យបានលំដាប់ថ្នាក់ទី១រហូតដល់ទី៩ទី១០ឬទី២០...


សុខារី ចៅ

លោក ថាយ ជុន បេក្ខជនក្រុមប្រឹក្សាក្រុងថ្មីម្នាក់ទៀត រីករាយណាស់នឹងគាំទ្រជម្រើសទី១ ដែលមានក្រុមប្រឹក្សាចំនួន៨+៣រូប ពីព្រោះប្រជាពលរដ្ឋ នឹងសប្បាយចិត្តក្នុងការជ្រើសយកបេក្ខជនដែលខ្លួន ស្គាល់រស់នៅក្បែរគ្នាមានបញ្ហាដែលត្រូវដោះស្រាយដូចគ្នា... ខ្ញុំមិនជឿថា បេក្ខជន ដំបន់ដ៏ទៃអាចនឹងប្រជែងអ្នករស់ក្នុងតំបន់ដូចគ្នាបាន ទេ។


ថាយ ជុន

លោក រ៉ិតនី អេលីយ៉ុតបច្ចុប្បន្នជាសមាជិកក្រុមប្រឹក្សាក្រុងនឹងជាបេក្ខជនសម្រាប់អណត្តិថ្មីផង បាននិយាយថា: គំនិតប្ដូរវិធីបោះឆ្នោត គឺមិនចង់ឱ្យសហគមន៍នៃតំបន់ណាមួយមានឥទ្ធិពលផ្ដាច់មុខទៅលើឡូវែលទាំងមូលតែម្នាក់ឯង ហើយ

តទៅទំព័រទី០៣


រ៉ិតនី អ៊ីលីយ៉ុត



មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare
and Other Health Insurances
Our Staff Speaks Khmer

# ព្យុះសង្ឃរា DORIAN បានសម្លាប់មនុស្ស ៤៣នាក់នៅប្រទេសបាហាម៉ាស

ព្យុះសង្ឃរាដ៏កំណាចដែលមានឈ្មោះ Dorian គិតមកត្រឹមថ្ងៃសុក្រ បានសម្លាប់មនុស្សកើនឡើងរហូតដល់៤៣ នាក់ ហើយចំនួនអ្នកស្លាប់រំពឹងថា នឹងកើនឡើងយ៉ាងខ្លាំងដោយសារតែកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញ កំពុងត្រូវបានបន្តធ្វើនៅប្រទេស បាហាម៉ា ដែលបានទទួលរងនូវការបំផ្លិចបំផ្លាញ។ ជាងនេះទៅទៀត មានមនុស្សចំនួនប្រហែលជាង ៧0,000 នាក់ កំពុងតែត្រូវការជំនួយនៅលើកោះ Abaco និង Grand Bahama ហើយរាប់ពាន់នាក់ទៀតកំពុងតែស្វែងរកគ្រួសារ និងអ្នកជាទីស្រឡាញ់របស់ខ្លួន។ នៅក្នុងហេតុការព្យុះសង្ឃរាដ៏កំណាចនេះ មានមនុស្សជាច្រើនត្រូវបានបាត់ខ្លួន។

វ៉ិបសាយ និងបណ្តាញសង្គមចំបងត្រូវបានបង្កើតឡើងកាលពីសប្តាហ៍នេះនៅពេលដែលព្យុះកំពុងតែបក់បោកទៅលើកោះនេះ ដោយធ្វើការស្នើរឱ្យសាច់ញាតិទាំងអស់ដាក់នូវព័ត៌មានដូចជាឈ្មោះ, ថ្ងៃខែឆ្នាំកំណើត, អាយុ, ទីកន្លែងកំណើត និងទីតាំងដែលត្រូវបានឃើញចុងក្រោយរបស់អ្នកដែលបាត់ខ្លួន ដើម្បីងាយស្រួលក្នុងការស្វែង។ គិតមកត្រឹមថ្ងៃសុក្រនេះ មានមនុស្សច្រើនជាង ៦,៦៦0 នាក់ មានឈ្មោះក្នុងបញ្ជីនាក់បាត់ខ្លួននៅក្នុងវ៉ិបសាយ Dorian People Search Bahamas។ ទន្ទឹមនឹងនេះដែរ គណនីហ្វេសបុកដែលមានឈ្មោះថា Pritchard-Ansell ក៏មានសមាជិកប្រហែល ១១,000 ដែលកំពុងតែស្វែងរកក្រុមគ្រួសាររបស់ពួកគេ។

ចំណែកលោកប្រធានាធិបតីអាមេរិក លោក ដូណាល់ ត្រាំបានមានប្រសាសន៍កាលពីថ្ងៃអាទិត្យថា "នាយករដ្ឋមន្ត្រីនៃប្រទេសបាហាម៉ាស លោក ហ៊ូបឺត មីននីស (Hubert Minnis) បាក្រ់លោកថា ជំនួយដែលផ្តល់ដោយសហរដ្ឋអាមេរិក បានជួយសម្រាលចំពោះការបំផ្លិចបំផ្លាញនេះ និងការបាត់បង់អាយុជីវិតដោយសារព្យុះសង្ឃរាដ៏កំណាចនេះ។ "ហើយលោកត្រាំ ក៏បានសសេរនៅក្នុង Twitter ថា " សូមថ្លែងអំណរគុណដល់លោកនាយករដ្ឋមន្ត្រី ហ៊ូបឺត មីននីស ចំពោះពាក្យសម្តីល្អ និងដ៏សប្បុរសរបស់លោកដោយបាននិយាយថា បើគ្មានជំនួយពីសហរដ្ឋអាមេរិកនិងលោកទេ នឹងមានចំនួនអ្នករបួសនិងស្លាប់ជាច្រើនទៀតជាមិនខាង។



ព្យុះសង្ឃរា ដូរីយ៉ាន បានបក់បោកក្នុងកំរិតលេខ៥ មានល្បឿន១២0គីឡូម៉ែត្រក្នុង១ម៉ោងមកលើកោះបាហាមា បណ្តាលអោយមានការខូចខាតជាសំណង់ដល់អាយុជីវិតមនុស្ស ទ្រព្យសម្បត្តិ និងដំណាំដាំដុះគ្រប់យ៉ាង

តមកពីទំព័រទី ០២ ## ប្រជាមតិ...

ជម្រើស ទី១ គឺ៨+៣ ជាជម្រើស ដែលប្រសើរសម្រាប់តំបន់និមួយៗឱ្យអាចមានតំណាងរបស់ខ្លួនបានមិនអាចឱ្យមានឥទ្ធិពល ដូចពេលមុនបានទេ, មានសមាជិកក្រុមប្រឹក្សាជាច្រើន បានការពារជម្រើសមួយនេះ...ចំណែកគំនិតដែលថាបេក្ខជនអាចឈរឈ្មោះនៅតំបន់ផ្សេងពីកន្លែងដែលខ្លួនរស់នៅបាននោះ ខ្ញុំយល់ថា វាមិនត្រឹមត្រូវទេ គេមុខតែនឹងប្តូរឬដកចេញនៅមុនពេលបោះឆ្នោតរបៀបថ្មីចាប់ផ្តើមជាមិនខាន។

សំនួរប្រជាមតិទាំង២យ៉ាងនេះ នឹងត្រូវលើកឡើងនៅពេលបោះឆ្នោតជុំទី២ ក្នុងសន្លឹកឆ្នោតនាខែវិច្ឆិកា ខាងមុខ, មានការវិភាគថា ជម្រើសទី២-មានការលំបាកនឹងអនុវត្តន៍ ហើយថា នេះជាចំណូលចិត្តរបស់មេធាវីដើមបណ្តឹងតែប៉ុណ្ណោះ។ តែទោះជាយ៉ាងណា គេសង្ឃឹមថា របៀបបោះឆ្នោតថ្មី នឹងធ្វើឱ្យអ្នកចេញទៅបោះឆ្នោតនៅឡូវែល នឹងកើនចំនួនច្រើនជាងមុនជាមិនខាននោះទេ។


គ្មានសហបង់ថ្លៃ—ជារៀងរហូត

គ្មានការបង់ថ្លៃសម្រាប់ការណាត់ជួបវេជ្ជបណ្ឌិត គ្មានការបង់ថ្លៃសម្រាប់ការថែទាំធ្មេញ គ្មានការបង់ថ្លៃសម្រាប់សេវាថែទាំភ្នែក

Senior Whole Health (HMO SNP) គឺជាផែនការសុខភាព Medicare Advantage មួយសម្រាប់ជនជរាអាយុ 65 ឆ្នាំឡើងទៅ ដែលមាន Medicare និង MassHealth Standard។ សមាជិកទទួលបានអត្ថប្រយោជន៍ Medicare និង MassHealth ទាំងអស់របស់ពួកគេ រួមទាំងការធានារ៉ាប់រងលើឱសថមានវេជ្ជបញ្ជា Part D។ លើសពីនេះ យើងបន្ថែមច្រើនទៀតដូចជា៖

- ប័ណ្ណអ្នកមានសុខភាពល្អ (Healthy You Card) ដើម្បីទិញថ្នាំគ្មានវេជ្ជបញ្ជា និងទំនិញទាក់ទងនឹងសុខភាពមួយចំនួន *(អ្នកទទួលបាន $100 ក្នុងមួយឆមាស រហូតដល់ $400 ក្នុងមួយឆ្នាំ)*
- អ្នកផ្តល់ជំនួយតាមផ្ទះជួយអ្នកក្នុងរឿងចំណីអាហារ និងការចល័ត
- ការធ្វើដំណើរទៅមកពីកន្លែងណាត់ជួបពិនិត្យសុខភាព
- សមាជិកម្នាក់ៗទទួលបានអ្នកគ្រប់គ្រងសេវាថែទាំសុខភាពដែលសម្របសម្រួលការមើលថែទាំរបស់អ្នក ដើម្បីឆ្លើយតបនឹងតម្រូវការជាបុគ្គលរបស់អ្នក



គម្រោងមួយ។ ប័ណ្ណមួយ។ Senior Whole Health។

*Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធ ដែលត្រូវបានអនុវត្ត និងមិនរើសអើងពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទឡើយ។ ATTENTION: If you speak a language other than English, language assistance services, free of charge, are available to you. Call 1-888-794-7268 (TTY 711). ATENCIÓN: si hablas español, tienes a su disposición servicios gratuitos de asistencia lingüística. Llame al 1-888-794-7268 (TTY 711). ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-888-794-7268 (TTY 711).*

Senior Whole Health (HMO SNP) និង Senior Whole Health NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលជាមួយនឹងកិច្ចសន្យាអត្ថប្រយោជន៍ Medicare និងកិច្ចសន្យាជាមួយរដ្ឋម៉ាសាជូសេត/កម្មវិធីសុខភាពសាធារណៈ EOHHS MassHealth។ ការចុះឈ្មោះអាស្រ័យលើការបន្តកិច្ចសន្យាពល់ឆ្នាំ។ ផែនការនេះអាចប្រើបានសម្រាប់អ្នកដែលមានអាយុ 65 ឆ្នាំឡើងទៅដែលទទួលជំនួយវេជ្ជសាស្ត្រពីរដ្ឋនិង Medicare។ H2224_2019_71805

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម ហៅទូរស័ព្ទ៖
**1-888-566-3526**
**(TTY 711)**
**www.seniorwholehealth.com/SNP**
ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍

ប្រសិនបើអ្នកមាន MassHealth Standard តែពុំមានការធានា Medicare ផ្នែក A និង/ឬ ផ្នែក B ទេ អ្នកអាចនឹងមានសិទ្ធិចុះឈ្មោះក្នុងកម្មវិធី MassHealth Senior Care Options (SCO)។

# បោះឆ្នោតក្រុមប្រឹក្សាក្រុងនៅឡូវែល ជុំទី១ ថ្ងៃអង្គារទី២៤ កញ្ញា ឆ្នាំ២០១៩

ដោយ ពិន សំខុន

ដោយសារបេក្ខជនក្រុមប្រឹក្សាក្រុងមានចំនួនដល់ទៅ២០រូប ជាចំនួនលើសពី១៨រូប ដែលបានកំណត់ចំនួនច្រើនបំផុតសម្រាប់ឱ្យមានការបោះឆ្នោតតែ១ ជុំនោះ, គណកម្មការរៀបចំការបោះឆ្នោតក្រុងតម្រូវ ឱ្យមានការបោះឆ្នោត២ជុំគឺ: ជុំទី១ នឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៤កញ្ញា ២០១៩ គឺបេក្ខជនចំនួន២រូប ដែល ទទួលបានសន្លឹកឆ្នោតតិចជាងគេ នឹងត្រូវជម្រុស ចោល... ហើយការបោះឆ្នោតនៅជុំទី២ ប្រព្រឹត្តទៅ នៅថ្ងៃទី៥ខែវិច្ឆិកា ឆ្នាំដដែល សម្រាប់យកបេក្ខជនណាដែលទទួលសន្លឹកឆ្នោតច្រើនជាងគេចំនួន៩រូប នឹងក្លាយទៅជាសមាជិកក្រុមប្រឹក្សាក្រុងឡូវែល នា ដើមខែមករាឆ្នាំ២០២០។

(រូបថតបេក្ខជនទាំង២០រូប)

រីឯគណកម្មការសាលារៀនឡូវែលត្រូវមាន សមាជិក៦រូប ចំណែកឯបេក្ខជនឈរឈ្មោះមាន ១១រូប នឹងត្រូវជ្រើសតាំងថ្ងៃទី៥វិច្ឆិកា ២០១៩ ជា មួយគ្នានឹងសមាជិកក្រុមប្រឹក្សាក្រុង ដោយការបោះ ឆ្នោតសាកលជុំទី២។

នៅជាមួយនឹងសន្លឹកឆ្នោតដែលលោកអ្នកនឹង បោះឆ្នោតឱ្យបេក្ខជនក្រុមប្រឹក្សាក្រុង នាជុំទី២នោះ សាលាក្រុងនឹងមានតាំងសំនួរប្រជាមតិស្តីពីវិធីបោះ ឆ្នោតរបៀបថ្មី២យ៉ាង ជូនលោកអ្នកជាម្ចាស់ឆ្នោត ឱ្យជ្រើសយក១ សម្រាប់វិធីបោះឆ្នោតនៅលើកក្រោយ នៅឆ្នាំ២០២១គឺ: -ជម្រើសទី១ (by Districts) ការបោះឆ្នោតរើសតំណាងតាមសង្កាត់រៀងខ្លួន -ជម្រើសទី២ ការបោះឆ្នោតតាមលំដាប់ថ្នាក់ចំណូល ចិត្ត (by Ranked choise) នៃម្ចាស់ឆ្នោត ។

របៀបបោះឆ្នោតថ្មីនោះហើយ គឺជាចុងបញ្ចប់ នឹងជាលទ្ធផលនៃបណ្តឹងរបស់ជនជាតិអាមេរិកាំង ភាគតិចចំពោះសាលាក្រុងឡូវែល។



# 2019 City Council Who's Running

Updated 08/24/2019 - List is in Ballot Order
lowellvotes.org/whosrunning

These 20 candidates will face off in a September preliminary for the right to proceed to the November general election. Then, the top nine vote getters will become the new Lowell City Council!

LOWELL VOTES

I INCUMBENT CITY COUNCILOR — PREVIOUS COUNCIL SEAT HOLDER




**Vesna Nuon** (Incumbent)
Highlands
Twitter: N/A
Facebook: vesnaforlowell
Instagram: N/A
vesnaforlowell.com




**Jeff Thomas**
South Lowell
Twitter: N/A
Facebook: Jeff4CityCouncil
Instagram: N/A
No Website




**Corey Belanger** (Previous council seat holder)
Belvidere
Twitter: N/A
Facebook: BelangerForLowell
Instagram: N/A
No Website




**Alexandra Del Villar**
South Lowell
Twitter: N/A
Facebook: delvillarforlowell
Instagram: N/A
No Website




**Marty Lorrey** (Previous council seat holder)
Belvidere
Twitter: N/A
Facebook: martylorrey
Instagram: N/A
No Website




**John Drinkwater**
Belvidere
Twitter: jm_drinkwater
Facebook: j.m.drinkwater
Instagram: drinkwaterforlowell
drinkwaterforlowell.com




**Ty Chum**
Highlands
Twitter: N/A
Facebook: chumforlowell
Instagram: N/A
chumforlowell.com




**Dave Ouellette**
The Acre
Twitter: N/A
Facebook: daveforyoulowell
Instagram: N/A
daveforyou.com




**Dave Conway** (Incumbent)
Belvidere
Twitter: N/A
Facebook: N/A
Instagram: N/A
No Website




**Juan Carlos Castañeda**
The Acre
Twitter: N/A
Facebook: Juan-Castaneda-for-Lowell-City-Council -1044477808039287
Instagram: N/A
juancastaneda.org




**Bill Samaras** (Incumbent)
Belvidere
Twitter: N/A
Facebook: samarasforlowell
Instagram: N/A
No Website




**Rita Mercier** (Incumbent)
Belvidere
Twitter: N/A
Facebook: N/A
Instagram: N/A
No Website




**Sokhary Chau**
Highlands
Twitter: N/A
Facebook: sokharychau
Instagram: N/A
No Website




**Karen Cirillo** (Incumbent)
Centralville
Twitter: Karen4Lowell
Facebook: Karen4Lowell
Instagram: N/A
karen4lowell.com




**Harry Kortikere**
Belvidere
Twitter: harry_kortikere
Facebook: harryforlowell
Instagram: N/A
harryforlowell.com




**John Leahy** (Incumbent)
Belvidere
Twitter: Jleahy62John
Facebook: LeahyforLowell
Instagram: N/A
councilorjohnleahy.com




**Rodney Elliott** (Incumbent)
Pawtucketville
Twitter: Rodney_Elliott1
Facebook: rodneyelliottforcitycouncil
Instagram: rodneye_1960
voterodneyelliott.com




**Marty Hogan**
Centralville
Twitter: Hogan4Lowell
Facebook: FriendsOfHogan4Lowell
Instagram: hogan4lowell
MartyHogan4Lowell.com




**Jose "Willie" Negron**
Highlands
Twitter: N/A
Facebook: jose.negron.9461799
Instagram: N/A
No Website




**Daniel Rourke** (Previous council seat holder)
Pawtucketville
Twitter: N/A
Facebook: N/A
Instagram: N/A
No Website

## Important Election Dates

SEPTEMBER
- 4 — Register to Vote in Preliminary
- 24 — Preliminary Election

OCTOBER
- 16 — Register to Vote in General

NOVEMBER
- 5 — General Election

**Someone missing? Got more info?**

Get in touch with us at info@lowellvotes.org

# ការបើកសម្ពោធឡើងវិញនៅថ្ងៃទី ១ ខែមិនា ខាងមុខនេះ



សូមមកធ្វើការណាត់ជួបជាមុននៅពេលឥឡូវនេះ

ហើយទទួលបានឧបករណ៍ធ្វើឲ្យធ្មេញសដោយមិនគិតថ្លៃ

យើងនិយាយភាសាខ្មែរ

ទទួលយកធានារ៉ាប់រងពីក្រុមហ៊ុនធំ និងរដ្ឋ

DRACUT FAMILY DENTAL

## ពេទ្យធ្មេញ

TOP DENTISTS 2018 AWARDED BY BOSTON MAGAZINE

**Dracut Family Dental**
14 Loon Hill Road • Dracut, MA 01826
978-955-9005
dracutdental@gmail.com

# Bundle up for savings

When you choose Allstate to protect what matters most, you get an expert agent who will make it easy for you to save. Like with bundling your insurance. It's the simplest way for you to save time and money, while getting protection for the things that matter most. Stop by or call today and let's get you bundled up.



**Chennara Kim**
**Associate Agent**
**The Wicks Insurance Group, Inc.**
**978-710-7040**
83 Parkhurst Road
Chelmsford, MA 01824
chennarakim@allstate.com

យើងខ្ញុំអាចនិយាយភាសាខ្មែរ

Allstate. You're in good hands.

Subject to terms, conditions & availability. Savings vary. Allstate Vehicle and Property Insurance Co., Allstate Insurance Co. © 2019 Allstate Insurance Co.

9966453



## CONWAY INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

**យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :**

**ការធានារ៉ាប់រងគ្រួសារ**
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

**ការធានារ៉ាប់រងជំនួញ**
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វើកខម (Worker's Compensation)
- បុនដ៍ (Bonds)
- អ្នកមើលថែម្យាន និងការរាស់ម្យាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

# ការប្រណាំងយានជំនិះចម្លែក (កិនតេិច) ប្រចាំឆ្នាំ លើកទីបួនក្នុងក្រុងឡូវែល, រដ្ឋម៉ាសាជូសេត

អ្នកទស្សនារាប់ពាន់នាក់បានងាកមកមើលរូបយានជំនិះចម្លែក និងមានទំហំប៉ុនឡាន និងធ្វើការប្រជែងតាមរយៈឧបសគ្គនៃការរួមបញ្ចូលគ្នានៃវិទ្យាសាស្ត្រ, បច្ចេកវិទ្យា, វិស្វកម្ម, សិល្បៈ, និងគណិតសាស្ត្រ។

ពេលវាលា: ថ្ងៃសៅ ទី២១ ខែកញ្ញា ឆ្នាំ ២០១៩

ទីតាំង: ឡូវែល, រដ្ឋម៉ាសាជូសេត នៅចំនុចប្រសព្វនៃផ្លូវ Market nig Plamer

ផ្លូវ: (Link to MAP: https://tinyurl.com/ydasdt59)

ម៉ោង: ៩:00 ព្រឹក - ការកំសាន្តចាប់ផ្តើម-មើលចម្លាក់, ជួបជាមួយនឹងអ្នកប្រណាំង និងរីករាយជាមួយនឹងក្រុមដន្ត្រី Party Band និងការសម្តែងដោយ Cirque de Light (Market Street) ១១:00 ព្រឹក -ការបើកកម្មវិធី, ការប្រណាំងយានជំនិះដែលមានរូបរាងចម្លែក និងមានជាច្រើនទៀត (pøÚv Market Street)

១១:៣0 ព្រឹក - ចាប់ផ្តើមការប្រណាំង! យន្តជំនិះទាំងអស់ធ្វើដំណើរឆ្ពោះទៅកាន់ Bone Shaker Alley (Market Street & Middle Street) ១២:៣0 រសៀល - Jeanne D'Arc នៅទីតាំង the Credit Union Lot ហើយក្រុមទាំងអស់នឹងឆ្លងកាត់ឧបសគ្គ MADDENING MUD PIT ១:៣0រសៀល -យន្តជំនិះដែលចូលរួមការប្រណាំងទាំងអស់ ចូលទៅកាន់ the Water Obstacle (DCR Lowell Heritage State Park and VFW Highway) ៣:៣0រសៀល -បញ្ចប់ការទស្សនា (Market Street) ៥:៣0 ល្ងាច -កម្មវិធីបិទជាផ្លូវការនៃការប្រណាំងយានជំនិះបន្ទាប់ពីពិធីជប់លៀង និងការប្រគល់រង្វាន់ជាមួយនឹង Warp

តទៅទំព័រទី ០៩



Photo Credit: LKR Facebook's page

# 2019 LOWELL KINETIC SCULPTURE RACE IS SET FOR SATURDAY, SEPT 21

By KhmerPost USA

Lowell's Kinetic Sculpture Race — is an all day day-long free event and one of the "must see" events in Lowell. It is the 4th Annual that attracts thousands of spectators from the region to watch the amazing race of human-powered vehicles made from repurposed materials with the calculations from math, science, engineering, technology, and twist of art. It is fun to watch for all ages.

The event is set to began at the intersection of Market and Palmer (Link to MAP: https://tinyurl.com/ydasdt59)

These sculptures will tackle mud, sand, water on the Merrimack River, cobblestones in downtown Lowell, and pavement over the course of the day as teams compete against one another for glory.

"The LKSR is such an important event for the City of Lowell and the Merrimack Valley." said Tom Fitzmaurice, Executive Director of the Greater Merrimack Valley Convention and Visitor's Bureau, "We are able to showcase how connected our natural resources are in Lowell with teams competing on both land and water. It's a great economic driver during the fall that brings thousands of visitors to the city. More importantly, it combines all the great things that Lowell is known for in one event; art, culture, natural beauty, and innovation, while also giving back to the local STEM community."

Spectators can follow the race

continued to Page 09






# លោក សម រង្ស៊ី បំពងសម្លេងសារជាថ្មី តើគួរឱ្យជឿប៉ុណ្ណា?ប៉ុណ្ណា?

ដោយ ពិន សំខុន

មនុស្សជាច្រើន បានស្តាប់ការបំពងសម្លេងយ៉ាងខែងរឹងរបស់លោក សម រង្ស៊ី ពីអូស្ត្រាលីកាលពីសប្តាហ៍មុននេះ, ស្តីពីចលនាសង្គ្រោះជាតិរបស់លោកកំពុងតែត្រៀមទៅរំលំរបប ហ៊ុន សែន ដោយមានការកាំទ្រដោយប្រជាពលរដ្ឋរាប់លាននាក់... មែន ឬមិនមែន គេចង់តែជឿអតីតមេបក្សប្រឆាំងមួយនេះដែរ ពីព្រោះតែគេត្រូវការឱ្យមានមេដឹកនាំម្នាក់មកទប់ទល់នឹងរបបលោក ហ៊ុន សែន ដែលបានរំលាយលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា, ប៉ុន្តែដូចសព្វមួយដងលោក សម រង្ស៊ី នៅតែបំបែកអារម្មណ៍រំខានអ្នកស្តាប់ជាខ្លាំង មិនត្រឹមតែគេមិនអាចជឿបានតែប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យមានការឈ្លោះប្រខាំគ្នារវាងអ្នកគាំទ្រសង្គ្រោះជាតិរឹតតែធ្ងន់ធ្ងរថែមទៀត ទៅវិញ។

លោក សម រង្ស៊ី ថ្លែងថា: "លោកនឹងទៅស្រុកខ្មែរថ្ងៃទី៩វិច្ឆិកា២០១៩ ខាងមុខនេះ - ហើយលោកនឹងទៅចាប់ ហ៊ុន សែន ដកចេញពីអំណាច ហើយអំពាវនាវឱ្យបងប្អូនខ្មែរក្រោកឈរឡើង ដើម្បីឱ្យជួយចាប់ជនផ្តាច់ការនោះឱ្យគាត់ផង" ចម្លែកណាស់ ស្តាប់ទៅឮសូរដូចតារាកំប្លែង ព្រហ្ម ម៉ាញ កាន់តែខ្លាំងឡើង...លោកដឹងហើយថា: ១-ហ៊ុន សែន មុខតែបញ្ជាឱ្យចាប់ខ្លួន ឱ្យតែហ៊ានទៅមែនមិនពិបាកយល់ទេ នៅពេលលោកហក់ទៅចូលចំណោមហ្វូងខ្លាហើយនោះ ២-មានការអ្វីបន្ទាន់ឬ បានជាបង្ខំ"លោតចូលភ្លើងយ៉ាងដូច្នេះ? តាមពិតទៅអ្នកដែលត្រូវប្រញាប់នោះគឺ ហ៊ុន សែន ឯណោះទេ ពីព្រោះមហាអំណាចគេសម្ញើញដាក់ទណ្ឌកម្មមន្ត្រីជាន់ខ្ពស់ខ្មែរ ៣-គេមិនឃើញលោក សម រង្ស៊ី បង្ហាញគម្រោងរបស់លោក



លោក សម រង្ស៊ី និងមកដល់ឡូវែលថ្ងៃទី១៥កញ្ញា

ឬមានការរៀបចំណាមួយឱ្យស្របនឹងបំណងចូលទៅស្រុកខ្មែរ ដែលជាប្រទេសឃោធានិយមនៅឡើយទេ។ រួមសេចក្តីទៅគេយល់ថា "សម រង្ស៊ី មិនអាចចូលកម្ពុជាដោយសុវត្ថិភាពបានទេ បើហ៊ុន សែន មិនយល់ព្រម!"។

អ្នកវិភាគឯករាជ្យជាច្រើន បានវាយតម្លៃថា "សម រង្ស៊ី នឹងភូតភរម្តងទៀត"ជាមិនខាន, ឱកាសដែលលោកមានសម្រាប់ធ្វើសេចក្តីថ្លែងការរបៀបនេះ បានកន្លងហួសឆ្ងាយទៅហើយ, កាលពីឆ្នាំ២០១៣ពេលបោះឆ្នោតរួច អ្នកសង្កេតការទាំងអស់ឱ្យលោកឈ្នះ ៦៣ទល់៦០ -ប្រជាពលរដ្ឋបះពេញទាំងនគរដើម្បីគាំទ្រសង្គ្រោះជាតិនឹងនិមិត្តរូប សម រង្ស៊ី-កឹម សុខា តែមួយ ...តែលោកបែរជាឃាត់ចលនាមនុស្សបះបោរនាពេលនោះ ហើយបានទទួលយកលទ្ធផលចាញ់ គឺ៥៥ ទល់នឹង៦៨ទៅវិញ ហេតុអ្វី? មន្ត្រីរបស់លោកនិយាយពេញមាត់ថា លោកបាន"ស៊ីឈ្នួលចាញ់",... ឥឡូវវាស្ងប់ស្ងាត់ខុសគ្នាពិពេលមុន ដែលពលរដ្ឋមានបុព្វហេតុនឹងបះបោរខ្លាំងណាស់...តែលោកបែរជាឃាត់កុំឱ្យមានការបះបោរទៅវិញ! ។

លទ្ធផលនៃវោហាសាស្ត្ររបស់ សម រង្ស៊ី នាពេល នេះ មិនបានធ្វើឱ្យ ហ៊ុន សែន នឹងគណបក្សប្រជាជនឈឺចាប់ណាមួយទេ មានតែសើចចំអកតែប៉ុណ្ណោះ... ក៏ប៉ុន្តែបែរជាបានធ្វើឱ្យសង្គ្រោះជាតិបែកបាក់គ្នារឹតតែខ្ទេចទៅៗ ពីព្រោះអ្នកដែលមិនជឿហើយទៅភ្នំពេញជាមួយ សម រង្ស៊ី ត្រូវគ្នាលោក សម រង្ស៊ី ចោទថា: គឺជាពួកកាន់ខាង ហ៊ុន សែន នឹងទៅបំរើបក្សប្រជាជន។ "ការពិត"មិនមានតម្លៃអ្វីសម្រាប់ សម រង្ស៊ី ទៀតទេ មានតែយកជ័យជំនះតែម្នាក់ឯងប៉ុណ្ណោះ ដែលសំខាន់...គួរឱ្យស្តាយ! ។

ថ្ងៃ១៥ខាងមុខនេះមានសេចក្តីប្រកាសមួយនិយាយថា លោក សម រង្ស៊ី នឹងមកធ្វើការឃោសនាកៀងគរសមាជិកសង្គ្រោះជាតិនៅទីក្រុងឡូវែល ឱ្យចូលរួមដំណើរជាមួយលោកទៅកាន់ប្រទេសកម្ពុជានៅថ្ងៃទី៩ ខែវិច្ឆិកា ២០១៩ខាងមុខ ដើម្បីទៅរំដោះជាតិខ្មែរពីរបបផ្តាច់ការ ហ៊ុន សែន ។ នៅឡូវែលមន្ត្រីជាន់ខ្ពស់សង្គ្រោះជាតិគាំទ្រលោក សម រង្ស៊ី ជាច្រើនបានចេញមកពីភ្នំពេញមកតាំងទីនៅទីនោះ ដែលជាហេតុធ្វើឱ្យមានការរួមប្រជុំនៅថ្ងៃទិ១៥កញ្ញានេះ, តែគេមិនបានឮពីក្រុមដែលគាំទ្រលោក កឹម សុខា ដែលមានកុះករនៅទីក្រុងជាមួយគ្នាដែរនោះ ថាបានដឹងឮ នឹងអញ្ជើញឱ្យទៅចូលទៅរួមប្រជុំក្រៅតែពីខិតប័ណ្ណដែលទើបតែនឹងចេញផ្សព្វផ្សាយកាលពីថ្ងៃទី៩នេះទេ។

សំណាងល្អដែរដែលនៅមានក្រុមសង្គ្រោះជាតិផ្សេងទៀត ស្មោះត្រង់នឹង លោក កឹម សុខា មានយ៉ែម ប៉ុញ្ញាឫទ្ធ នាង កឹម មនោវិជ្ជា ង៉ោ គឹមឈៀង ធ្វើការដោយស្ងាត់ស្ងៀម... តែមានប្រសិទ្ធភាពខ្លាំងដោយអាចធ្វើឱ្យប្រទេសមហាអំណាចសេរីចេញមកជួយពលរដ្ឋខ្មែរ, ខិតខំឱ្យគេដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរលើរដ្ឋបាលភ្នំពេញទាល់តែបាន... ធ្វើបានប៉ុណ្ណឹងហើយ នៅតែត្រូវក្រុមគាំទ្រលោក សម រង្ស៊ី ជេរប្រទេះឆ្អេះគ្នាមិនឈប់ឈរទៀត! ។







តមកពីទំព័រទី ០៥

# ការប្រណាំងយាន្តជំនិះចម្លែក...

និង Weft (Market Street) ការប្រណាំងយានជំនិះដែលមានរូបរាងចម្លែកនៅឡូវែល ដែលគេតែងតែហៅថា "Triathlon of the Art World" គឺព្រឹត្តការណ៍បែបគ្រួសារ និងការឆ្នៃប្រឌិត ដែលរួមមានយាន្តជំនិះចម្លែកៗដែលឆ្នៃប្រឌិតឡើងនៅតាមគេហដ្ឋានដូចជាយានយន្តដំណើរការដោយការប្រើកំលាំងមនុស្ស និងមានកង់ធំៗធ្វើឡើងដោយប្រើប្រាស់ឡើងវិញនូវសម្ភារៈចាស់ៗដែលបានប្រើរួចហើយជាមួយនឹងការផ្លាស់ប្តូរបែបសិល្បៈ។ យាន្តជំនិះទាំងអស់នឹងឆ្លងកាត់ឧបសគ្គផុត, ទឹក, ដុំថ្ម, និងថ្លល់កៅស៊ូពេញមួយថ្ងៃដោយធ្វើការប្រណាំងប្រជែងជាមួយនឹងអ្នកប្រណាំងផ្សេងទៀតដើម្បីដណ្តើមជ័យជំនះ។ ខណៈដែលរង្វាន់នឹងត្រូវផ្តល់ដល់អ្នកដែលចំណាយពេលលឿនបំផុត គោលដៅនៃការប្រណាំង គឺដើម្បីបង្កើតទស្សនីយភាពរីករាយបែបគ្រួសារសម្រាប់បុគ្គលគ្រាប់អាយុ និងសាវតារទាំងអស់។



ការចូលរួមមិនគិតថ្លៃ និងបើកចំហរជាសាធារណៈ។ ការប្រណាំងជំនិះដែលមានរូបរាងចម្លែក គឺជាកម្មវិធីធ្វើឡើងពេញមួយថ្ងៃដែលអស្ចារសម្រាប់មនុស្សគ្រាប់វ័យទាំងអស់។ អ្នកទស្សនាទាំងអស់អាចមើលការប្រណាំងនៅទីតាំងឧបសគ្គផ្សេងៗជុំវិញក្រុងឡូវែលទល់នឹងអ្នកប្រណាំង និងបុគ្គលិករៀបចំកម្មវិធី ហើយអាចរីករាយនឹងការប្រគុំតន្ត្រីផ្ទាល់។

លោក ថូម ហ្វីតម៉ូរាយ (Tom Fitzmaurice) នាយកប្រតិបត្តិនៃការិយាល័យការអ្នកទស្សនា និងមហាសន្និបាទក្រេតធ័រ ម៉ារីម៉ាក វ៉ាលី បានមានប្រសាសន៍ថា "ប្រណាំងយានជំនិះដែលមានរូបរាងចម្លែកនៅឡូវែល គឺជាព្រឹត្តការណ៍ដ៏សំខាន់បែបនេះសម្រាប់ក្រុងឡូវែល និងម៉ារីម៉ាក វ៉ាលី។" លោកបានបន្ថែមទៀតថា "យើងអាចបង្ហាញពីវិធីសាស្ត្រនៃការភ្ជាប់ធនធានធម្មជាតិរបស់យើងក្នុងក្រុងឡូវែលជាមួយក្រុងទាំងអស់ដែលប្រណាំងទាំងផ្លូវគោក និងទឹក"។ វាគឺជាចលករសេដ្ឋកិច្ចដ៏សំខាន់មួយក្នុងកំឡុងរដូវឈើជ្រុះស្លឹកដែលបាននាំអ្នកទស្សនាជាច្រើនពាន់នាក់មកកាន់ក្រុងឡូវែល។សំខាន់ជាងនេះទៅទៀតព្រឹត្តការណ៍នេះប្រមូលផ្តុំអ្វីៗដែលល្អៗទាំងអស់ដែលល្បីនៅក្រុងឡូវែលតែក្នុងព្រឹត្តការណ៍មួយនេះ ដូចជាសិល្បៈ, វប្បធម៌, សម្រស់ធម្មជាតិ និងការឆ្នៃប្រឌិតជាមួយគ្នានោះដែរក៏ផ្តល់ត្រឡប់មកវិញនូវសហគមន៍ក្នុងស្រុកនូវវិទ្យាសាស្ត្រ, បច្ចេកវិទ្យា, វិស្វកម្ម, និងគណិតសាស្ត្រ។

សម្រាប់ព័ត៌មានបន្ថែម សូមលោកអ្នកចូលទៅកាន់ www.lowellkinetic.com រឺ www.facebook.com/lowellkinetic




## 2019 LOWELL KINETIC

*/ From Page 07*

and watch different obstacles at various locations by following the schedule below:

9:00am - Festivities Begin- see the sculptures, meet the racers and enjoy the sounds of the Party Band and performances by Cirque de Light (Market Street)

11:00am - Opening Ceremonies, the LKSR Oath and more (Market Street)

11:30am - START the race! Sculptures head to Bone Shaker Alley (Market Street & Middle Street)

12:00pm - Jeanne D'Arc at the Credit Union Lot and teams tackle the MADDENING MUD PIT

1:30pm- Sculptures enter the Water Obstacle (DCR Lowell Heritage State Park and VFW Highway)

3:00pm - The Spectacular Finish (Market Street)

5:00pm- The official LKSR After Party and Awards Ceremony with Warp and weft (Market Street)




# DIVERSITY
## ADULT DAYCARE CENTER

"ទីកន្លែងដែលអ្នកជាទីស្រលាញ់របស់លោកអ្នក អាចហៅថា ជាផ្ទះ"

**តើអ្វីទៅជាមជ្ឈមណ្ឌលថែទាំចាស់ជរា?**

យើងខ្ញុំយល់ឃើញថាក្នុងនាមជាអ្នកផ្តល់សេវាថែទាំពេញម៉ោង គឺជាការងារមិនងាយស្រួលនោះទេ។ នៅពេលពអ្នកជាទីស្រឡាញ់ដែលមានវ័យកាន់តែចាស់ ត្រូវការការថែទាំ រឺការមើលការខុសត្រូវក្នុងកំឡុង ពេលព្រឹក រឺពេលថ្ងៃនោះ វាអាចបង្កើតឱ្យមានអារម្មណ៍ស្មុកស្មាញដល់អ្នកមើលថែក្នុងគ្រួសារ។ គ្រួសារជាច្រើនគិតថាពួកគេគ្មានជម្រើសអ្វីក្រៅពីឈប់ធ្វើការងារ រឺឱ្យមានអ្នកមកមើលថែអ្នកដែលជា ស្រលាញ់របស់ខ្លួនដល់លំនៅដ្ឋាន រឺកន្លែងថែរទាំចាស់ជរា។ មជ្ឈមណ្ឌលថែទាំចាស់ជរា ដាយវ៉ឺស៊ីធី ដែលភាសាអង់គ្លេស Diversity Adult Daycare Center (DADC) មានផ្តល់ទីកន្លែងគ្រប់គ្រងដែលមានសុវត្ថិភាពដែលអ្នកដែលមានវ័យចំណាស់អាចធ្វើការទាក់ទងនឹងមនុស្សឯទៀត, រីករាយជាមួយនឹងសកម្មភាពផ្សេងៗ និងទទួលបានជំនួយថែទាំ។ ទីកន្លែងនេះវានឹងមិនធ្វើឱ្យលោកអ្នក ដែលជាអ្នកមើលការខុសត្រូវចំពោះពួកគាត់មានការបារម្ភអ្វីទាំងអស់ នៅពេលពួកគេមានការណាត់ជួប, ភារៈកិច្ចការងារ រឺមានពេលវេលាសម្រាប់ខ្លួនឯងខ្វាល់ផងដែរ។

**អត្ថប្រយោជន៍នៃសេវាថែទាំចាស់ជរា**

ចូលរួមជាមួយនឹងមជ្ឈមណ្ឌលថែទាំចាស់ជរា នឹងមានអត្ថប្រយោជន៍វិជ្ជមានជាច្រើនដល់ជនចាស់ជរា។ អ្នកជាទីស្រលាញ់ក្នុងគ្រួសាររបស់លោកអ្នកមិនចាំបាច់នៅផ្ទះដែលធ្វើឱ្យមានអារម្មណ៍ឯកកោរដោយគ្មានការជុំរុញលើកទឹកចិត្តផ្នែកស្មារតីនោះទេ នៅពេលអ្នកមើលថែទាំងពួកគាត់ជាប់រវល់។ ការមកកាន់មជ្ឈមណ្ឌលថែទាំចាស់ជរាបង្កើតឱ្យមាននូវអារម្មណ៍ថា ស្ថិតនៅក្នុងសហគមន៍មួយដែលពួកគាត់អាចមានភាពរីករាយ និងមាននូវសុខភាពល្អជាមួយនឹងសកម្មភាពជាច្រើននៅក្នុងមជ្ឈមណ្ឌល។ អ្នកជាទីស្រឡាញ់របស់លោកអ្នកនឹងទទួលរង់ចាំក្នុងការទទួលបានឯករាជ និងជួបជាមួយនឹងមិត្តភ័ក្រ្ត។ មេត្រីភាពដែលលោកអ្នកមានជារៀងរាល់ថ្ងៃជំរុញឱ្យមានអារម្មណ៍នូវតំលៃខ្លួនឯង និងមិត្តភាព។

**សេវាកម្មដែលយើងខ្ញុំផ្តល់ជូននៅ DADC:**

- អាហារ និងនំចំណីបំប៉នច្រើន
- ថ្នាក់កីឡារជាក្រុម
- ថ្នាក់សម្រាប់ការសិក្សា
- ដំណើរកំសាន្ត និងការចេញទៅខាងក្រៅជាក្រុម
- ការលេងល្បែងកំសាន្ត និងសកម្មភាពរីករាយប្រចាំថ្ងៃ ជំនួយក្នុងការថែទាំ
- សេវាផាតមុខ និងធ្វើសក់
- ការដឹកជញ្ជូន
- ការរៀបចំកម្មវិធីខួបកំណើតប្រចាំខែ
- បុគ្គលិកផ្នែកពេទ្យ
- សកម្មភាពដាំបន្លែ

**តើនរណាជាបេក្ខភាពសមស្របសម្រាប់មជ្ឈមណ្ឌលថែទាំចាស់ជរា DADC**

- មានអាយុចាប់ពី ៥៥ និងចាស់ជាងនេះ
- ជនជាតិអាស៊ីអាគ្នេយ៍ និងស្ពែនីស
- ទីតាំងយើងខ្ញុំងាយស្រួលសម្រាប់ជនពិការចេញចូលជ

**របៀបនៃការបង់ប្រាក់ដែលយើងខ្ញុំទទួលយក**

- យើងខ្ញុំទទួលយកការបង់ប្រាក់ជាឯកជន
- ទទួកយករាល់ធានារ៉ាប់រងចំបងៗទាំងអស់

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

យើងខ្ញុំនិយាយភាសាអង់គ្លេស, ស្ពេនីស, ខ្មែរ, ឡាវ, ម៉ោង, បំទុយក្កាល់, សូវៀត និងតាហ្គាលុក។ សូមអញ្ជើញមកទស្សនាកន្លែងមជ្ឈមណ្ឌលយើងខ្ញុំ។ យើងខ្ញុំនឹង ផ្តល់នូវការពិនិត្យវាយតំលៃ និងជំនួយក្នុងការដាក់ពាក្យដោយមិនគិតថ្លៃ។ ទទួលយករាល់ការធានារ៉ាប់រងចំបងៗ និងការទូទាត់ប្រាក់ជាឯកជនទាំងអស់។ សម្រាប់ធានារ៉ាប់រង មេឌីឃេត សម្រាប់សេវាថាទាំចាស់ជរាលោកអ្នកមិនចាំបាច់ចំណាយអ្វីទាំងអស់។




## KhmerPost USA, LLC
## សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក



**អគ្គនាយក សុបិន្ត ពិន**
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
sobenpin@khmerpost.us



**និពន្ធនាយកខ្មែរ** Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
(978-942-1641| rogerpin@khmerpost.us



Richard Howe Jr.
Contributed Writer | Editor

**ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន**
Advertising Contact
Soben Pin
Cell: 979-656-8141
sobenpin@khmerpost.us

**អ្នកនិពន្ធកិត្តិយស** Staff Writer| Translator
Sokharath Koy

**ច្នៃសោភ័ណ្ឌភាព** Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

សារព័ត៌មាន ខ្មែរផុស ស.រ.អ
KhmerPost USA

## Now Coming to California!

The state of California has the highest concentration of Cambodians in the country with over 35% residing in the greater Los Angeles area. According to the Census Bureau, there are **116,822 Cambodians** living in California, **41,459** in Los Angeles County, and **19,784** in the City of Long Beach.

With the expansion in California, **The KhmerPost USA** will bring relevant news and information, in both Khmer and English, in the **free** biweekly newspaper publication. We have the same commitment and dedication to our readers and advertisers that we have provided for the past 10 years to the Cambodian communities in New England.

- New Format! - Monthly Magazine Style
- Local News Relevant to the greater Long Beach Area
- Excellent Advertising Opportunities
- New Completive Rates!
- For additional information call: 714.486.3060

Celebrating 10 Years of Service

# REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY

## WITH COST EFFECTIVE NEWSPAPER ADVERTISING

KhmerPost USA

### DISTRIBUTION

*70+ Locations in Lowell, MA*
*7,000 copies per month*

*25 Locations in Lynn & Revere, MA*
*1,000 copies per month*

*25 Locations in Providence & Cranston, RI*
*2,000 copies per month*

Lowell
Lynn
Revere
Providence
Cranston

### PUBLISHING

*Two Issues Every Month*

### READERSHIP

*50,000 Monthly*
*600,000 Annually*

**Khmer Post USA Distribution Locations Include:**

- Households
- Markets
- Retail Businesses
- Restaurants
- Office Buildings
- Government Offices
- Chamber of Commerce
- Buddhist Temples
- Laundromats
- And Much More

| 2019 PRINTING DATES | 2019 PRINTING DATES |
|---|---|
| 7Jan and 21 | 8 July and 22 |
| 4 Feb and 18 | 5 Aug and 19 |
| 4 March and 18 | 9 Sept and 23 |
| 8 April and 22 | 7 Oct and 21 |
| 6 May and 20 | 9 Nov and 23 |
| 10 Jun and 24 | 6 Dec and 20 |

*Advertising deadlines are 5 business days prior to printing date.*

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue | 3 Months (6 Issues) 5% Savings | 6 Months (12 Issues) 7.5% Savings | 12 Months (24 Issues) 10% Savings |
|---|---|---|---|---|
| **Full** (10" x 13") | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10" x 6.5") | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5" x 6.5") | 165 | 940 | 1831 | 3,564 |
| **1/8** (5" x 3.25") | 90 | 513 | 999 | 1,944 |

### CONTACT INFO

27 Jackson St. Unit 329 Lowell, MA 01852
**Tel: 978.677.7163 • Fax: 978.677.7092 • Email: sobenpin@khmerpost.us**
**www.khmerpost.us**

*Khmer Post USA is a proud member of the Greater Lowell Chamber and Greater Merrimack Valley Convention and Visitors Bureau*

CELEBRATING 10 YEARS

# ម្ហូបអាហារស្រស់ៗពីកសិដ្ឋានក្នុងស្រុកមាន លក់នៅផ្សារចល័ត ម៉ាល ស៊ីធី ក្រូ ទូទាំងក្រុងឡូវែល

ចាប់ពីថ្ងៃអង្គារ៍រហូតដល់ថ្ងៃអាទិត្យ បន្លែ និងផ្លែឈើដែលដាំនៅក្នុងស្រុកស្រស់ៗនឹងមានការដាក់តាំងលក់នៅទីតាំងចំនួន១១កន្លែងដែលមានឈ្មោះថា ផ្សារចល័តម៉ាលស៊ីធីក្រូ (Mill City Grows Mobile Market) ទូទៅក្រុងឡូវែល ។ ភាគច្រើននៃបន្លែ និងផ្លែឈើទាំងអស់ គឺដាំនៅកសិដ្ឋានដែលមានទីតាំងនៅឡូវែលតែម្តងដូចជាកសិដ្ឋាន Urban Farm ស្ថិតនៅ Mill No. 5, កសិដ្ឋាន Urban





Agriculture Greenhouse នៅ UMass Lowell និងកសិដ្ឋាន Big Farm នៅឯ Pawtucketville ។

រាល់ការទិញលក់នៅគ្រប់ទីតាំងផ្សារចល័តទាំងអស់ គឺទទួលយកប្រាក់សុទ្ធ, ក្រេឌីតកាត, សែក, ប័ណ្ណ SNAP, វ៉ីក (WIC), និងប័ណ្ណបញ្ចុះតំលៃ (Senior Coupons) ។

ប្រសិនបើលោកអ្នកមានប័ណ្ណ SNAP, សូមលោកអ្នកប្រាប់ទៅកាន់បុគ្គលិកនៅទីនោះថា លោកអ្នកមានប័ណ្ណ SNAP ហើយលោកអ្នកនឹងទទួលបាន $1 រាល់ការទិញបន្លែនិងផ្លែឈើដែលបានកំណត់ដោយគម្រោងរហូតដល់ក៏រិតកំណត់ប្រចាំខែ តាមរយៈអត្ថប្រយោជន៏នៃគម្រោងលើកទឹកចិត្តផ្នែកសុខភាពនៃរដ្ឋម៉ាសាជូសេត (Healthy Incentives Program) ។

អ្វីដែលសំខាន់នោះគឺថា លោកអ្នកត្រូវមានសមតុល្យនៃប័ណ្ណ NAP ដើម្បីទទួលបានអត្ថប្រយោជន៏ពីគម្រោងលើកទឹកចិត្តផ្នែកសុខភាព(HIP) ។ ចំនួនថវិការអតិបរិមាពីគម្រោង HIP ដែលលោកអ្នកទទួលបាន គឺអាស្រ័យទៅលើទំហំគ្រួសាររបស់លោកអ្នកៈ

| ទំហំគ្រួសារ | ថវិការទទួលបានប្រចាំខែពីគម្រោង HIP |
|---|---|
| ១-២ នាក់ | $40 |
| ៣-៥ នាក់ | $60 |
| ៦ + នាក់ | $80 |

ដូច្នេះវិកាយប័ត្រដែលបានមកពីទិញនឹងបង្ហាញឱ្យលោកអ្នកឃើញពីចំនួននៃអត្ថប្រយោជន៏នៃការលើកទិកចិត្តនៃគម្រោង HIP របស់លោកអ្នកបន្ទាប់ការរទិញរបស់លោកអ្នក ។ ចំនួនថវិការដែលលោកអ្នកទទួលបានពីគម្រោង HIP នឹងត្រូវដាក់បញ្ចូលត្រឡប់ទៅក្នុងប័ណ្ណគណនី SNAP របស់លោកអ្នកវិញ ។ លោកអ្នកអាចប្រើប្រាស់នូវថវិការដែលបានទទួលគម្រោងនេះភ្លាមៗ រឺអាចសន្សំទុកសម្រាប់ការទិញលោកក្រោយទៀត ។ អត្ថប្រយោជន៏ដែលលោកអ្នកទទួលបាននេះ អាចប្រើប្រាស់គ្រប់ទីកន្លែងណាដែលទទួលយកនូវប័ណ្ណ SNAP ។

សម្រាប់ព័តិមានបន្ថែមពីគម្រោងលើកទឹកចិត្តផ្នែកសុខភាពនៃរដ្ឋម៉ាសាជូសេត (Healthy Incentives Program) សូមទំនាក់ទំនងទៅកាន់សេវាបំរើអតិថិជន EBT តាមរយៈលេខទូរសព្ទ័ (800) 997-2555 ។ លោកអ្នកក៏អាចទូរសព្ទ័ដើម្បីចង់ដឹងចំនួនថវិការដែលលោកអ្នកទទួលបានពីគម្រោង HIP ក្នុងមួយខែៗក៏បាន ។ សូមបញ្ជាក់ថា គម្រោងកម្មវិធីនេះ មិនត្រូវបានអនុវត្តពេញមួយឆ្នាំនោះទេ ដូច្នេះសូមទំនាក់ទំនងទៅកាន់សេវាបំរើអតិថិជនសម្រាប់ព័តិមានទាំងអស់នេះ ។

ប្រសិនបើលោកអ្នកចងដឹងព័តិមានពីទីតាំងនិងពេលវេលានៃការរៀបចំផ្សារចល័ត សូមទូរសព្ទ័ទៅកាន់អង្គការម៉ាលស៊ីធីក្រូតាមលេខ 978-455-2620 ។ លោកអ្នកក៏អាចដឹងពីពេលវេលា នៃផ្សារចល័តនេះតាមរយៈវិបសាយ www.millcitygrows.org រឺ ហ្វេសប៊ុកផេច www.facebook.com/MCGMobileMarket រឺ www.instagram.com/millcitygrowsmm ។






# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

**AccuCare**
Home Care Agency
Group Adults Foster Care Program

***ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។***

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide
បុគ្គលិកមានសណ្ដានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- *រស់នៅផ្ទះរដ្ឋ*
- *អាយុ ២២ ឆ្នាំឡើងទៅ*
- *មានសុខាភិបាលស្តង់ដា*

**ផលប្រយោជន៍ទទួលបាន :**

- *ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ*
- *ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក*
- *ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមាន៉ីជើ*
- *វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់*
- *សមាជិកអាចទាក់ទងមក២៤ម៉ោង*

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**

To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# New Chief of Behavioral Health at LCHC



Lynn Community Health Center is pleased to announce that Carlos Cappas, will become its new Chief Behavioral Health Officer on Monday, September 9.

A strong advocate for the integration of primary care and behavioral health services, Dr. Cappas' career has focused on addressing the clinical, administrative and operational barriers to fully integrated care.

Dr. Cappas' has held clinical and administrative leadership roles at two Federally Qualified Community Health Centers in Massachusetts where he witnessed both the successes of collaborative care as well as the clinical and operational barriers that can make care difficult. Ultimately, this is what led him to seek out more administrative roles to complement his clinical expertise and to focus on strategies that address the complex behavioral and social issues that impact care, particularly for underserved communities.

Dr. Cappas most recently worked at Boston Children's Hospital, where he was responsible for the implementation of quality improvement activities, operational training, and clinical integration for 12 pediatric primary care practices. Before that, he served at the Massachusetts Behavioral Health Partnership (MBHP) where he provided administrative and operational consultation to a large network of primary care practices interested in building integrated behavioral health services.

"At Lynn Community Health Center," he said, "I look forward to building relationships with patients, clinicians, staff and community partners in order to collaboratively work towards deepening the integration of primary care and behavioral health services, while providing quality of care in a fiscally sustainable and patient-centered manner."

"Dr. Cappas' wealth of experience in policy, primary care/behavioral health integration, performance improvement and interdisciplinary leadership will serve the Lynn Community Health Center well," said Dr. Kiame Mahaniah, CEO. "He is the behavioral health leader we need as we tackle the challenge of a new MassHealth payment model, and new ways for funders and payors to evaluate the quality of our work.

Dr. Cappas is a native of Puerto Rico and received his doctoral degree from Ponce Health Sciences University and completed at two-year post-doctoral fellowship in Clinical Health Psychology in Primary Care at UMass Medical School. He also holds an MBA in Healthcare Management from UMass Boston.

COMM UNITY TEAM WORK

## "កិច្ចប្រជុំក្រុមប្រឹក្សា"

កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា"កុំមូនីធី ទីមវើក" បានត្រូវកំណត់នៅថ្ងៃពុធ ទី២៥ កញ្ញា ២០១៩ វេលាល្ងាច ម៉ោង៧គត់
នៅ១៥៥ផ្លូវមេរីម៉ាក ជាន់ទី២ បន្ទប់"ម៉ាជូរី ម៉ាក់ឌ័រមូទ" - សាធារណជនសូមស្វាគមន៏

## BOARD MEETING

Community Teamwork monthly board meeting is scheduled on Wednesday, Sept 25th, 2019 at 155 Merrimack Street. Marjorie McDermott Board Room. 2nd Floor. Lowell, MA 01852. Meetings are called to order promptly at 7:00 P.M. Public is welcome.


ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration • អន្តោប្រវេសន៏
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com



ការិយាល័យច្បាប់
រ៉ូសា និង តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា



Andrew 'Bunna' Taing, Esq.
មេធាវី អែន ឌ្រីវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

SERVICES
- Auto Accidents/ Personal Injury
- Bankruptcy
- Immigration
- Consumer Protection
- Real Estate Closings/Disputes
- Divorces Child Custody

តំណាងក្តីដូចខាងក្រោម
- គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
- ក្ស័យធន
- អន្តោប្រវេសន៏
- ការពារអតិថិជន
- ទិញលក់ផ្ទេរអចលនវត្ថុ
- លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: 978-458-0934 | at@rosataing.com



ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេត
URBAN REAL ESTATE

មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន
Residential Leasing Center



ដាញ៉ែល តាន
ភ្នាក់ងារអចលនៈទ្រព្យ
Daniel Tan
Real Estate Agent
Cell: 978-902-6354

508 Westford Street • Lowell, MA 01851
(978) 454-0444



ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនស្ជូរិន អេជេនស៊ី
KK Insurance Agency, Inc.

រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
Car • Home • Business



508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com

# មណ្ឌលពិនិត្យសុខភាពឡូវែល

# Lowell Primary Care Center

**លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.**
**Sokharith Mey, M.D.**

**លោក ឆាន់ ទូច , C.N.P.**
**Chhan Touch, C.N.P.**





## ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ
***Family Medicine***

&

សុខភាពផ្លូវចិត្ត
***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហែល, មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking